# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២០ នៅក្រុមហ៊ុន ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា) ប្លាស្ទិក អិនដាស្ទ្រី ខូអិលធីឌី បានបើកកិច្ចប្រជុំមួយក្រោមធិបតីភាព កញ្ញា LIN YING HSIN (លីន អ៊ីង ស៊ីន) ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារអតិថិជន (ខាងសហភាពអឺរ៉ុប និង សហរដ្ឋអាមេរិក) ផ្អាកការបញ្ជាទិញ រយៈពេលមួយខែ។

សមាសភាពចូលរួមៈ

1-ភាគីតំណាងរោងចក្រ

- កញ្ញា LIN YING HSIN (លីន អ៊ីង ស៊ីន)ជាតំណាងប្រធានផ្នែកទីផ្សាររោងចក្រ
- លោកស្រី ហ៊ឹម ចាន់ផល្លា ជាប្រធានរដ្ឋបាលរោងចក្រនិងជាអ្នកកត់ត្រា

2-ភាគីតំណាងកម្មករនិយោជិក

- លោក ស៊ុយ វាសនា
- លោក លន ចក

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងខាងក្រោមៈ

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៥១ នាក់ ក្នុងចំណោមកម្មករសរុបចំនួន១២៥ ក្នុងរយៈពេល១ខែ ដោយគិតចាប់ពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២០។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យានេះ។

3- ក្រុមហ៊ុននិងផ្តល់ប្រាក់ឧបត្ថម្ភ ចំនួន ៣០ ដុល្លាក្នុងមួយខែនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០។

4- ចប់ការព្យួរការងារកម្មករនិយោជិតត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៥ ៖ ៣០នាទីនា ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃទី ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០

| | |
|---|---|
| បានឃើញនិងឯកភាព | បានឃើញនិងឯកភាព |
| តំណាងនាយកក្រុមហ៊ុន | តំណាងកម្មករ |
| ព្រះរាជាណាចក្រកម្ពុជា ស៊ីន ស៊ី អេក អិន ហុង (ខេមបូឌា) ប្លាស្ទិក អិនដាស្ទ្រី SIN CHN HONG (CAMBODIA) PLASTICS INDUSTRY CO.,LTD. 林穎欣 | ស៊ុយ វាសនា លន ចក |